# ការណែនាំ

ស្តង់ដារពិការភាព
សំរាប់ការអប់រំ



# ការគោរព
# នៅសាលា

ធនធាននេះសំរាប់សិស្សដែលមានពិការភាព មាតា បិតា និងអ្នកថែរក្សា និងសាលាទាំងឡាយអោយបានរៀនដឹងពីអាកប្បកិរិយាដែលប្រកបដោយក្តីគោរព និងពីហេតុសំខាន់ដែលត្រូវគិតដល់សិស្ស ដែលមានពិការភាពកាលណាធ្វើការសំរេចចិត្ត។

**ធនធាននេះត្រូវបានផ្តែដោយសិស្សនិងក្មេងដែលមានពិការភាព និងមាតាបិតានិងអ្នកថែរក្សា។**

## អំពីធនធាននេះ

ធនធាននេះត្រូវបានទទួលមូលនិធិពីរដ្ឋាភិបាលអូស្ត្រាលី។ វាត្រូវបានផ្ដៃដោយមាតាបិតានិងអ្នកថែរក្សាក្មេងដែលមានពិការភាព រួមនឹងជំនួយពី**កុមារនិងក្មេងដែលមានពិការភាពអូស្ត្រាលី** (Children and Young People with Disability Australia - CYDA) និងការបញ្ចូលអូស្ត្រាលី (Inclusion Australia)។

រដ្ឋាភិបាលអូស្ត្រាលីទទួលស្គាល់ម្ចាស់ទឹកដីដើមនិងអ្នកថែរក្សាប្រទេសទូទាំងប្រទេសអូស្ត្រាលី។ យើងទទួលស្គាល់ដល់ទំនាក់ទំនងដ៏និរន្តន៍ជាមួយដី ទឹក និងសហគមន៍របស់គេ។ យើងសូមគោរពដល់ពួកគេនិងដល់  ពួកចាស់ទុំពីអតីតកាលនិងបច្ចុប្បន្នកាល។ យើងសូមគោរពដល់ការអនុវត្តផ្នែកវប្បធម៌ ព្រលឹងវិញ្ញាណ និងការអប់រំនៃជនអាបូរិជិនល និងពួកកោះTorres Straight។

## កំណត់សំគាល់ពីភាសា

ធនធាននេះប្រើភាសាបុគ្គលមុន (ឧ. សិស្សដែលមានពិការភាព)។ ប៉ុន្តែវិធីនេះមិនសមនឹងមនុស្សគ្រប់រូប  ហើយមនុស្សជាច្រើនចូលចិត្តភាសាអត្តសញ្ញាណមុន (ឧ. សិស្សពិការ)។

វាស្រេចទៅលើបុគ្គលម្នាក់ៗ ដែលគេជ្រើសរើសសំគាល់ខ្លួនដោយរបៀបណា។ យើងសូមលើកទឹកចិត្តអ្នក អោយសួរគេថាគាត់ចូលចិត្តអ្វី។ យើងក៏ទទួលស្គាល់ប្រវត្តិសាស្ត្រដ៏ជ្រាលជ្រៅដែលនៅពីក្រោយពាក្យទាំងនេះដែរ។

ធនធាននេះគឺសំរាប់សិស្សដែលមានពិការភាព និងមាតាបិតានិងអ្នកថែរក្សា។ យើងប្រើពាក្យ ‘កូនរបស់អ្នក’ គឺមានន័យថាកូនណាដែលអ្នករ៉ាប់ទទួលខុសត្រូវ។

## ធនធានបន្ថែម

នេះគឺផ្នែកមួយនៃធនធានមួយក្រុម។ អ្នកអាចរកឃើញនៅក្នុងវ៉ែបសៃត៍នៃក្រសួងអប់រំ ឬដោយស្កេនកូដ QR

ធនធាននេះក៏មាននៅក្នុង Easy Read, Auslan និងភាសាផ្សេងៗមួយ
ចំនួនទៀត។ អ្នកអាចចូលមើលសំណេរទាំងនោះនៅវ៉ែបសៃត៍ Australian Government Department of Education ឬដោយស្កេនកូដ QR.

ស្កេនកូដ QR

***កំណត់សំគាល់មាតិកា:*** *ធនធាននេះនិយាយពីការរើសអើងនិងការធ្វើបាបនៅសាលា។ ហើយក៏មាននិយាយពីអារម្មណ៍អវិជ្ជមានដែលបណ្ដាលមកពីការនេះដែរ។ ចូរទូរស័ព្ទមក Lifeline តាមលេខ **13 11 14** ឬផ្ញើសារមកលេខ **0477 13 11 14** សំរាប់ការជួយគាំទ្រ។ អ្នកក៏អាចទាក់ទង Kids Helpline តាមលេខ **1800 55 1800** ផងដែរ។*

## ការណែនាំនេះសំរាប់អ្នកណា

ការណែនាំនេះគឺសំរាប់សិស្សដែលមានពិការភាព
និងសំរាប់មាតាបិតានិងអ្នកថែរក្សារបស់គេ។

## ការណែនាំនេះសំរាប់អ្វី

ការណែនាំនេះគឺសំរាប់ជួយអោយអ្នកយល់:

1. ថាគេគួរប្រព្រឹត្តយ៉ាងណាមកអ្នកនៅសាលា
2. ថាអ្នកមានសិទ្ធិក្រោមច្បាប់ *ស្តង់ដារពិការភាពសំរាប់ការអប់រំ 2005 (Disability Standards for Education 2005)* (DSE).

### អ្វីទៅជាស្តង់ដារពិការភាពសំរាប់ការអប់រំ 2005?

DSE ជាស្តង់ដារសំរាប់អប់រំសិស្សដែលមានពិការភាព ហើយជាផ្នែកមួយនៃច្បាប់អូស្ត្រាលី។

**ស្តង់ដារ**

ស្តង់ដារជាអ្វីដែលយើងប្រើសំរាប់វាស់ថាអ្វីដែលបានធ្វើគឺល្អប៉ុណ្ណា។
ស្តង់ដារជួយអោយយើងធ្វើយ៉ាងណាអោយអ្វីៗដើរបានល្អ។

**ស្តង់ដារDSE**

ស្តង់ដារDSE ពន្យល់នូវប្រការសំខាន់ពីរយ៉ាង:

1. សិទ្ធិរបស់សិស្សដែលមានពិការភាព
2. សាលាត្រូវធ្វើដូចម្តេចខ្លះដើម្បីជួយសិស្សដែលមានពិការភាពអោយទទួលសិទ្ធិរបស់គេ។

## ការណែនាំនេះនិយាយពីអ្វីខ្លះ

ការណែនាំនេះថ្លែងពីអ្វីទៅដែលហៅថាការគោរព ហេតុអ្វីបានជាវាសំខាន់
ហើយគ្រប់គ្នាអាចធ្វើការជាមួយគ្នាដោយរបៀបណា។ វានិយាយពី:

- តើការគោរពមានទំរង់ដូចម្តេចនៅសាលា?
- តើការគោរពមានអារម្មណ៍ដូចម្តេច?
- តើមានអ្វីកើតឡើងនៅពេលបាត់ការគោរព?
- តើត្រូវមានអ្វីកើតឡើងដើម្បីអោយមានភាពខុសគ្នា?

# តើការគោរពមានទំរង់ដូចម្តេចនៅសាលា?

ការគោរពត្រូវបានបង្ហាញឡើងនៅពេលយើងប្រព្រឹត្តិនិងទាក់ទងជាមួយបណ្តាជន។

## ការគោរពក្នុង
## របៀបយើងប្រព្រឹត្តដល់បណ្តាជន

អ្នកគួរទទួលការប្រព្រឹត្តដ៏ល្អនៅសាលា។ សាលាអ្នក
និងគ្រូគួរចាត់វិធានការដើម្បីធ្វើអោយអ្នកមានសុវត្ថិភាព។

**ច្បាប់អូស្រ្តាលីចែងថាការប្រព្រឹត្តមកអ្នកដោយមិនស្មើភាពគឺខុសច្បាប់:**

- ដោយព្រោះអ្នកមានពិការភាព
- ដោយព្រោះអ្នកបានត្អូញត្អែរអំពីអ្នកណាម្នាក់ដែលប្រព្រឹត្តមកអ្នក ដោយមិនស្មើភាពដោយព្រោះអ្នកមានពិការភាព។

បើអ្នកទទួលការប្រព្រឹត្តល្អ
នោះអ្នកទទួលការប្រព្រឹត្តដោយក្តីគោរព។

## ការប្រព្រឹត្តទៅបណ្តាជនដោយក្តីគោរពមានន័យថា:



អ្នកប្រព្រឹត្តដល់មនុស្សគ្រប់រូបដូចដែលអ្នកចង់អោយគេប្រព្រឹត្តមកអ្នក។
ប៉ុន្តែអ្នកមិនប្រព្រឹត្តទៅមនុស្សគ្រប់រូបដូចគ្នាទេ។
មនុស្សគ្រប់រូបខុសគ្នា។



អ្នកយល់ថាគ្រប់ៗគ្នារៀនដឹងតាមរបៀបខុសគ្នា ហើយតាមល្បឿនខុសគ្នា។
គ្រូរបស់អ្នកគួរបត់បែនខ្លះៗក្នុងរបៀបដែលគាត់បង្រៀនអ្នក។
អ្នកគួរបត់បែនខ្លះៗក្នុងរបៀបអ្នករៀនជាមួយមិត្តរួមថ្នាក់របស់អ្នក។



អ្នកដឹងពីស្ថានភាពរបស់អ្នកដទៃថាវាយ៉ាងណាឥឡូវនេះ។
នេះមានន័យថាអ្នកព្យាយាមយល់ដឹង:

- ពីអ្វីដែលកើតឡើងក្នុងជីវិតរបស់អ្នកដទៃ
- ថាគេមានអារម្មណ៍យ៉ាងណាដែរ។



កទទួលស្គាល់ថាអ្នកដទៃមានសិទ្ធិ:

- ជ្រើសរើសធ្វើអ្វីដែលគេចង់ធ្វើ
- នឹងមានឯកជនភាព
- នឹងមានពេលវេលាផ្ទាល់ខ្លួន។

ចូរចាំថា បើគេចង់អោប ឬប៉ះពាល់ ឬចាប់ដៃ គឺស្រេចទៅលើគេ។



អ្នកមិនត្រូវវិនិច្ឆ័យអ្នកដទៃដោយសារជំរើសឬចំណូលចិត្តរបស់គេទេ។ អ្នកអោយតំលៃដល់មតិរបស់គេ។ នេះនឹងធ្វើអោយគេកាន់តែមានទំនុកចិត្តដើម្បីបង្ហាញអារម្មណ៍ និងអ្វីដែលគេគិត។



អ្នកទទួលស្គាល់និងយោគយល់ដល់ភាពខុសគ្នានៃអ

- មតិ គំនិត និងជំនឿ
- អាយុ
- ប្រវត្តិ
- វប្បធម៌
- សាសនា
- អត្តសញ្ញាណភេទ និងផ្លូវភេទ
- ពិការភាព



អ្នកទទួលស្គាល់ថាគ្រប់ៗគ្នាជាមនុស្សម្នាក់។



យើងមិនអាចយល់ស្របនឹងអ្វីទាំងអស់ទេ។ ប៉ុន្តែទោះជាអ្នកមិនយល់ស្របនឹងអ្នកណាម្នាក់ សូមកុំភ្លេចធ្វើដោយសុភាពរាបសា។



អ្នកគោរពអ្នកដទៃសូម្បីតែអ្នកមិនចូលចិត្តគេក៏ដោយ។ អ្នកមិនចាំបាច់ចូលចិត្តអ្នកណាម្នាក់ដើម្បីគោរពគាត់ទេ។

## ការគោរពក្នុងរបៀបយើងប្រព្រឹត្តដល់បណ្តាជន

ការគោរពនៅសាលាគឺសំដៅទៅលើទំនាក់ទំនងជាមួយមាតាបិតា អ្នកថែរក្សា សិស្ស គ្រូ និងគ្រូជំនួយ។




### ចូរចងចាំ

- បើមាតាបិតា អ្នកថែរក្សា គ្រូ និងសិស្សយល់ដូចគ្នា នោះជាជំនួយដ៏ល្អមួយ។
- អ្នកគួរចៅរៅជាមួយគ្នា ហើយសំរេចចិត្តជាមួយគ្នា។ នេះសំខាន់ណាស់ ព្រោះនឹងមិនយល់ច្រឡំគ្នា។
- មុនដំបូងអ្នកប្រហែលជាមិនយល់ស្រប ប៉ុន្តែចូរព្យាយាមរក្សាក្តីគោរព។ អ្នកអាចនិយាយអោយបានជ្រាលជ្រៅជាងនេះជានិច្ចថាហេតុអ្វីបានអ្នកមិនយល់ស្រប។
- អ្នកនិងមិត្តរួមថ្នាក់របស់អ្នកគួរគោរពគ្នាទៅវិញទៅមកផងដែរ។ អ្នកគួរហៅគ្នាមកចូលរួមក្នុងសកម្មភាពនានា។

# តើការគោរពមានអារម្មណ៍ដូចម្តេច?






### ពេលអ្នកបង្ហាញក្តីគោរពអស់រយៈពេលយូរ

## សេចក្តីគោរពក៏ដុះលូតលាស់ទៅជាអ្វីដែលច្រើនជាងមុន




## ភាពងាយស្រួលជាផ្នែកមួយនៃការ

ភាពងាយស្រួលមានន័យថាអ្នកអាចយក ចូល ឬប្រើអ្វីមួយ។ មានដូចជាទីកន្លែង វត្ថុ សកម្មភាព ឬព័ត៍មាន។ សាលារបស់អ្នកបង្ហាញក្តីគោរពនៅពេលគេធ្វើអោយការទាំងនេះមានការងាយស្រួល។



ការទាំងនេះអាចជា:

- ការផ្តល់ឧបករណ៍ឬបច្ចេកទេសណាមួយ
- ការងារថ្នាក់រៀន
- ថ្នាក់រៀន
- អាគារសាលា
- ទីធ្លាលែងកំសាន្ត

អ្នកនឹងសាលារបស់អ្នកគួរធ្វើការជាមួយគ្នាដើម្បីធ្វើយ៉ាងណាអោយចូលរួមបាន។
អ្នកគួរចាប់ផ្តើមនិយាយអំពីការនេះអោយបានឆាប់ៗតាមធ្វើបាន។
ចូរព្យាយាមកុំចាំទំរាំដល់មានបញ្ហា។ អ្នកនិងសាលាអ្នកអាចដាក់គំរោងការបញ្ឈប់បញ្ហាមុននឹងវាកើតឡើង។

## ការរាប់បញ្ចូលជាផ្នែកមួយនៃការគោរព

គ្រូអ្នកនិងសាលាគួរ:

- រាប់បញ្ចូល
- ជួយគាំទ្រ។

អ្នកគួរចូលរួមសហគមន៍សាលា។

## តើមានអ្វីអាចកើតឡើងពេលបាត់ការគោរព?




### ពេលអ្នកដទៃមិនគោរពគ្នា នោះគេអាច:

- លែងទុកចិត្តអ្នក
- មិនគោរពរង្វង់ផ្ទាល់ខ្លួនរបស់អ្នក។

### ចូរចងចាំ

- នេះមិនមែនជាកំហុសរបស់អ្នកទេ។
- ការទុកចិត្តអាចចំណាយពេលយូរដើម្បីកសាង។ វាអាចចំណាយពេលទំរាំនឹងមានអារម្មណ៍ថាអាចទុកចិត្តអ្នកដទៃបាន។.
- អ្នកខ្លះទុកចិត្តមិនបានទោះចំណាយពេលប៉ុណ្ណាក្តី។ មានអារម្មណ៍ដូចនេះក៏មិនថ្វីទេ។
- អារម្មណ៍និងមតិរបស់អ្នកគឺសំខាន់។ នេះគឺពិតណាស់មិនថាអាយុឬស្ថានភាពរបស់អ្នកជាអ្វីនោះទេ។

# តើត្រូវមានអ្វីកើតឡើងដើម្បីអោយមានភាពខុសគ្នា?

## គន្លឹះសំរាប់សិស្ស

1. អ្នកគួរគោរពអ្នកដទៃ ហើយគេក៏គួរគោរពអ្នកដូចគ្នាដែរ។
2. បើអ្នកគិតថាមានអ្វីខុសឆ្គង ចូរនិយាយជាមួយមនុស្សដែលអ្នកទុកចិត្តបាន។ នេះអាចជាមាតាបិតា មិត្តភក្តិ គ្រូ ឬអ្នកណាផ្សេង។ ពួកគេអាចណែនាំអ្នកបើអ្នកត្រូវការជំនួយ។
3. ជំនួយពីក្រៅក៏មានដែរបើអ្នកត្រូវការ។ ឧ. អ្នកគាំទ្រឯករាជ្យម្នាក់អាចជួយអ្នកអោយសំរេចចិត្តបាន។ ដើម្បីរកអ្នកគាំទ្រ សូមមើលតាម (https://www.dana.org.au/find-an-advocate/)។

## គន្លឹះសំរាប់មាតាបិតានិងអ្នកថែរក្សា

1. ចូរមើលសញ្ញាដែលបង្ហាញថាកូនអ្នកត្រូវបានគេប្រព្រឹត្តមកដោយមិនល្អ។
2. កូនអ្នកអាចមករកអ្នកកាលមានបារម្ភអ្វីមួយ។ ចូរដាក់ផែនការថានឹងធ្វើអ្វីបើការនេះកើតឡើង។ ចូររកអ្នកនិយាយជាមួយនៅសាលា។
3. ចូររៀបចំការប្រជុំជាមួយអ្នក កូនអ្នក និងសាលា។ ដើម្បីរកមើលថានឹងបានដំណោះស្រាយអ្វីខ្លះ។
4. ធ្វើការជាមួយគ្នាដើម្បីកសាង ឬកសាងឡើងវិញនូវសេចក្តីគោរព។
5. មានជំនួយឯករាជ្យ ឧ. អ្នកគាំទ្រឯករាជ្យ។ គាត់អាចមានគំនិតថ្មីអំពីស្ថានភាព។ គាត់ក៏អាចជួយធ្វើគំរោងការណ៍ចាត់ការអោយបានសំរេច។ ដើម្បីរកអ្នកគាំទ្រ សូមមកមើល (https: /www.dana.org.au/ find-an-advocate/)។



## អ្វីដែលគ្រូនិងសាលាគួរធ្វើ

1. ទៅចៅរៅអោយបានស្គាល់សិស្ស និងអ្វីដែលចំរើនបំផុតសំរាប់ពួកគេ។
2. ប្រស្រ័យជាមួយសិស្ស មាតាបិតា និងអ្នកថែរក្សា។
3. សំរេចផែនការអោយបានដាច់ស្រេច។ ពន្យល់មូលហេតុបើមិនបានសំរេច។

## ព័ត៌មានបន្ថែមនិងជំនួយគាំទ្រ

- *ស្តង់ដារពិការភាពសំរាប់ការអប់រំ2005* (https://www.legislation.gov.au/Details/F2005L00767)
- *ច្បាប់រើសអើងពិការភាព1992* (https://www.legislation.gov.au/Details/C2018C00125)
- មជ្ឈមណ្ឌលពិការភាពអូស្ត្រាលី (https:/www.disabilityaustraliahub.com.au/) – បញ្ជីអង្គារពិការភាព
- ច្រកផ្លូវពិការភាព (https: /www.disabilitygateway.gov.au/) – តំណទៅសេវាកម្ម អ្នកគាំទ្រ និងព័ត៌មានអំពីការអប់រំកុមារភាពវ័យដំបូង
- គណៈកម្មាធិការសិទ្ធិមនុស្សអូស្ត្រាលី (AHRC) (https://humanrights.gov.au/)



www.education.gov.au/disability-standards-education-2005